# ពុទ្ធាទានកថា

រៀបរៀងដោយ

ឆយ - ស៊ីផាត

ពិនិត្យដោយ

សហជីវិន ហេង - យ៉ាន់

នាយកការិយាល័យក្រសួងហិរញ្ញវត្ថុ

បោះពុម្ពផ្សាយដោយ

ក្រសួងហិរញ្ញវត្ថុ

សូមឧទ្ទិសភាគផលដែលកើតពីធម្មទាន ចំពោះ
វិញ្ញាណក្ខន្ធសពសហជីវិន ហេង - យ៉ាន់ ដែលធ្វើ
មរណកាល កាលពីថ្ងៃទី ២៨ ឧសភា ១៩៦៧ ។

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

២០៦.
១១

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសីុ-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh  www.elibraryofcambodia.org

www.budinst.gov.kh  www.elibraryofcambodia.org

# ពុទ្ធោវាទគាថា

២០៦.១១

១–សូមសេចក្តីសុខចំរើនកើតមានដល់ពុទ្ធសាសនិកជន អ្នកមានកិរិយាគោរពនូវគុណព្រះរតនត្រ័យជាប្រក្រតី ។

២– សូមឲ្យឧបទ្ទវន្តរាយទាំងឡាយទាំងពួង វិនាសបាត់បង់ទៅដោយអានុភាពនៃគុណព្រះរតនត្រ័យនោះ ។

៣– អ្នកប្រាជ្ញលោកពោលថា នរជនណាបានដល់នូវ ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, ជាទីពឹង ទីរឭក នរជននោះ លោកសន្មតថាជាបុគ្គលប្រសើរលើសដោយពិត ។

៤– បុគ្គលណាមួយបានដល់ ព្រះត្រ័យរត្ន័ ជាទីពឹង ទីរឭក ហើយឃើញនូវអរិយសច្ចទាំង ៤ ដោយប្រាជ្ញាដ៏ត្រូវ បុគ្គលនោះរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះកាស្រ័យនូវទីពឹងនោះ ។

៥– បុគ្គលគប្បីស្វែងរកធម៌ដើម្បីកំចាត់ ឧបសគ្គទាំងពួង

—/—

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៦០៣៥/០២
www.budinst.gov.kh www.elibraryofcambodia.org

ចិត្ត ដែលជាហេតុនាំមកនូវសេចក្ដីសុខ-ចំរើន ព្រោះបាត ទុក្ខវេទនាគ្រប់យ៉ាង ។

៦- សទ្ធារបស់មនុស្សជាសភាវៈមិនទៀង នរជន កុំ គប្បីគិតថា អាត្មាអញនៅក្មេងហើយមិនស្វែងរកធម៌ ត្រូវគិតថា អាត្មាអញចាស់ហើយ មច្ចុរាជនឹងចាប់អញយកសម្លាប់ នូវពេលខាងមុខនេះមិនខាន ។

៧- នរជនណាមានសេចក្ដីជឿស៊ប់ក្នុងព្រះពុទ្ធសាសនា មានសីលល្អបរិសុទ្ធ មាន សេចក្ដីជ្រះថ្លានឹងព្រះសង្ឃផង មាន សេចក្ដីយល់ឃើញដ៏ត្រឹមត្រូវផង អ្នកជាបណ្ឌិតហៅបុគ្គល នោះថាមិនមែនជាអ្នកទាល់ក្រឡើយ ហើយជីវិតរបស់នរជន នោះមិនមែនសាបសូន្យឥតប្រយោជន៍ឡើយ ។

៨- នរអ្នកណា ទោះប្រុសក្ដី ស្រីក្ដី ឲ្យតែមានអភិរក្សនូវធម៌ និងគោរពតាមធម៌ក្នុងខ្លួន អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើមលោកពោលថា អ្នកនោះរមែងចំរើននូវតេជៈទាំងបួន



www.budinst.gov.kh www.elibraryofcambodia.org

ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ ។

៩ – ជនជនណាបានស្តាប់ត្រាប់ត្រង់ ដោយយកបញ្ញា មកត្រិះរិះពិចារណានូវពុទ្ធភាសិតនេះ ជនជនោះអាចនឹងស្គាល់ នូវធម្មសាររបស់ព្រះអរហន្តមុនីដោយពិត ហើយមានសេចក្តី សុខស្ងប់ទាំងក្នុងលោកនេះ និង លោកខាងមុខផង ។

១០ – ព្រះសម្មាសម្ពុទ្ធ បរមគ្រូជាម្ចាស់ ទ្រង់បាន សម្រេចនូវព្រះបារមីដោយសព្វគ្រប់ហើយ ព្រះអង្គមានព្រះ ករុណាមិនអត់អំពើទ្រង់តែងចូលនិព្វានទៅទេ យៀសត្វក្នុងៗបាយ ដើម្បី ត្រាស់ដឹង តាមសមគួរដល់ឧបនិស្ស័យ បើជនណាមួយបាន ស្តាប់នូវព្រះធម៌នោះឈ្មោះថាបានរួចស្រឡះចាកអាសវៈទាំង ឡាយដោយពិត ។

ដូ.ច្នះ ពុទ្ធភាសិតនេះនឹងនាំការម្មណ៍ សាធុជនទាំងឡាយ ឲ្យបានយល់ច្បាស់នូវព្រះធម៌ទាំងនោះដោយៗម្យ៉ាងផ្សេង ១ ដើម្បីត្រិះរិះពិចារណារកមាគ៌ាត្រាប់ទៅរកសេចក្តីសុខស្ងប់ ។



www.budinst.gov.kh www.elibraryofcambodia.org

១១ អនិច្ចតាធម៌ គឺសភាពមិនទៀងទាត់ ទុក្ខតាធម៌គឺសភាពជាទុក្ខ, អនត្តាធម៌គឺសភាពមិនមែនជារបស់ខ្លួន, ធម៌ទាំងបីយ៉ាងនេះ ពុំមែនជាធម៌នៃអ្នកស្រុក អ្នកនិគម ឬត្រកូលណាមួយទេ ប្រាកដជាធម៌សម្រាប់មនុស្សសត្វទាំងអស់ឥតមានអ្នកណាមួយជៀសផុតឡើយ ។

១២- ទុក្ខ ។ សង្ខារទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើងនិងវិនាសទៅវិញជាធម្មតា. តែកើតឡើងហើយរមែងរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយទើបបាននូវសេចក្ដីសុខគ្រប់យ៉ាង ។

១៣- សត្វទាំងឡាយទៀងតែពីស្លាប់ ព្រោះថាជីវិតរបស់សត្វទាំងនោះមាននូវសេចក្ដីស្លាប់ជាទីបំផុត ហើយរមែងនាំយកនូវផលបុណ្យ និងផលបាបតាមសមគួរដល់យថាកម្មរបស់ខ្លួន គឺអ្នកធ្វើល្អតែងបានឡើងទៅកាន់សុគតិភព អ្នកធ្វើអំពើអាក្រក់ តែងធ្លាក់ទៅសោយទុក្ខក្នុងនរកជាប្រាកដ ។



www.budinst.gov.kh www.elibraryofcambodia.org

១៤ – ព្រះមុនីជាធំឡើយលោកពោលដូច្នេះថា ៖

នរជនណាមានប្រាជ្ញាចង់បានសុខដល់ខ្លួន គួរតែប្រញាប់ធ្វើតែបុណ្យដែលជាគុណនាំអ្នកប្រាជ្ញឱ្យកាន់ឱ្យបានជាកិច្ចគឺខ្លួនត្រូវតែលាងសន្សំ គ្រាន់បានជាទីពឹងទៅក្នុងលោកខាងនាយ ។

បានឮមកថា កាលពីអតីតកប្បនិរលង់យូរណាស់ទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមព្រះបាទ សិរីធម្ម-ធនញ្ជ័យ: ទ្រង់ជាក្សត្រប្រកបដោយស្វាមីគុណជាធម្មិកប្រកបដោយទសពិធរាជធម៌ ។ ថ្ងៃមួយព្រះអង្គជាបតីទ្រង់គង់សោកព្រះកាយពេល ទំលាក់ព្រះអង្គលើព្រះខែនសយនា ក៏ទ្រង់ព្រះចិន្តាថា ៖

១៥ – ឱហ្ន៎ ! ព្រះរាជាទាំងឡាយតាំងពីបប់មានដែលប្រកបដោយបរិពលសកលយោធា តើសព្វថ្ងៃនេះស្តេចទៅគង់នៅទីណា ? មានតែផែនដីនេះទេដែលជាសាក្សី



www.budinst.gov.kh www.elibraryofcambodia.org

នៃការបាត់បង់ទៅនូវព្រះរាជាទាំងនោះ ។

១៦ - ពិតមែនកាលនេះកើតឡើងហើយ ក៏ជា

នូវការបែកឆ្ងាយទៅវិញ, ភោគសម្បត្តិកើតឡើងហើយ

ដល់នូវភោគវិបត្តិ, វត្ថុសព្វសារពើក្នុងលោក តែកើតឡើ

ហើយមុខជានឹងដល់នូវការពុកផុយទៅវិញជាធម្មតា ។

ព្រះឧរុខរពត ទ្រង់ពិចារណានូវសេចក្តីទាំងពីរប

" ១៥-១៦ " នេះហើយ ទ្រង់ក៏ផ្តួលព្រះរាជហឫទ័យជាខ្លាំ

ទើបទ្រង់បន្ទូលព្រះគាថា :

១៧ - មានប្រយោជន៍អ្វីហ្ន៎! ក្នុងការធ្វើខ្លួនឲ្យសប្បាយ

ភ្លេចគិតដល់សេចក្តីស្លាប់, ក៏រយោធ្វើអំពើអាក្រក់, ក៏រយ

មិនសាងអំពើបុណ្យ, ក៏រយោធ្វើចិត្តឲ្យវង្វេងក្នុងអំពើកាម

ទាំងនេះជាហេតុនាំមកនូវសេចក្តីវិនាស ។

កាលព្រះរាជាអង្គនោះទ្រង់ពិចារណានូវសេចក្តីទាំងនោ

ហើយ ព្រះអង្គទ្រង់គក់ស្មុគក្នុងព្រះទ័យជាអនេក ទើ



www.budinst.gov.kh www.elibraryofcambodia.org

ក្រោកចាកក្រឡាព្រះបន្ទំ បរមសយនា រៀបចំព្រះកាយាយាន ព្រះបាទាតែឯកាឆ្ពោះទៅកាន់ **ធម្មនាវាស** ដែលនៅទីនោះ មានជីគុនមួយអង្គព្រះនាម **ធម្មបទីប** គង់នៅ ។ លុះយាន ដល់ហើយព្រះភូមិបាលសំពុតគន្ធផ្ទង់អញ្ជលីថ្វាយបង្គំព្រះថេរៈ ហើយគង់ក្នុងទីដ៏គួរសម ។

ក្នុងពេលនោះព្រះ **ធម្មបទីប** ក៏សួរទៅកាន់ព្រះរាជាថា៖ បពិត្រមហារាជ ព្រះអង្គយាងមកនេះតើមានបការៈដូចម្តេចដែរ ។

រាជា ថេរៈ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាមកនេះមិនមានអ្វីក្រៅពីការដាក់ខ្លួនឲ្យនៅក្រោមឱវាទ គឺការខ្ញុំបានរបស់លោកម្ចាស់ទេ ព្រោះថា :

១៨ – ចិត្តរបស់មនុស្សប្រក្រតីដែលមិនទាន់អប់រំ នៅមានសភាពមិននឹងនរ តែងតែឃ្លេងឃ្លោងដោយអារម្មណ៍គ្រប់យ៉ាង ជួនបរទៅលើសភាវៈល្អ ជួនបរទៅលើសភាវៈ



www.budinst.gov.kh www.elibraryofcambodia.org

អាក្រក់ ព្រោះអារម្មណ៍ផ្សេង ៗ មានរូបារម្មណ៍ជាដើម ។

ដូច្នេះ ខ្ញុំករុណាសូមលោកម្ចាស់ប្រោសមេត្តាជួយណែនាំចិត្តនេះឲ្យបានស្ថិតនៅក្នុងសភាវៈល្អឲ្យបាន ។

លំដាប់នោះព្រះ **ធម្មបណ្ឌិត** ក៏មានព្រះថេរដីកាថា :

មហាកជ ព្រះធម៌របស់ព្រះអង្គនេះល្អណាស់ព្រោះថា :

១៩– សង្សារវដ្តនេះគ្មានខ្លឹមសារទេ កើតឡើងពេញដោយទុក្ខព្រួតព្រាវ គឺវេទនាដែលកើតអំពី **ជាតិ ជរា ព្យាធិ** និង **មរណៈ** ជនណាមួយលះបង់នូវសង្សារនេះបាន ទើបបានសុខ ។

២០– មច្ឆាដែលដើរចូលទៅជិតសន្ទូចលាក់ថ្វី ឯសត្វក៏ដើរចូលទៅជិតមច្ចុដែរ ដូចជាសត្វដែលគេនាំទៅកាន់កន្លែងសម្លាប់កល់ឋានដែរ ។

ដោយអាស្រ័យហេតុនេះ ទើបព្រះអង្គមានដោយត្រូវនឹងដឹកនាំសត្វឲ្យរួចចាកសង្សារនេះ ឲ្យបានដល់នូវផលជាទីក្សេម



www.budinst.gov.kh www.elibraryofcambodia.org

ក្សាន្ត ពីព្រះនិព្វាន ។

ទោះ! នរជនដែលបានទទួលនូវសេចក្តីសុខស្ងប់នោះ ប្រាកដជាបានអនុវត្តតាមពុទ្ធានុសាសន៍ដោយពិត ព្រោះថា ៖

៥១- កិរិយាមិនធ្វើបាបគ្រប់យ៉ាង ១ កិរិយាសាងនូវអំពើជាកុសល ១ កិរិយាធ្វើចិត្តឱ្យស្អាតផូរផង់ ១ ទាំងបីយ៉ាងនេះជាឫសគល់របស់សាសនា ជាហេតុនាំឲ្យនរជនបានទទួលនូវសន្តិភាព ទាំងក្នុងលោកនេះនិងលោកខាងមុខ ។

៥២- មហាភព មនុស្សពីពួក គឺមនុស្សល្អ និងមនុស្សអាក្រក់ ទាំងពីរនេះរមែងទទួលផលផ្ទុយពីគ្នា ដែលជាហេតុនាំឲ្យគេរក្នុងកិរិយាសាងនូវកុសល ។

៥៣- មនុស្សបាប ដរាបណាបើបាបមិនទាន់ឲ្យផលទេ ដរាបនោះរមែងជួបប្រទះតែអំពើល្អ លុះកាលណាបាបឲ្យផល កាលនោះមនុស្សបាបទើបជួបប្រទះនឹងអំពើបាប ។

៥៤- ពិតមែនហើយ មនុស្សល្អ ដរាបណាបើអំពើល្អ

www.budinst.gov.kh www.elibraryofcambodia.org

មិនទាន់ឲ្យផលទេ ដរាបនោះ រមែងជួបប្រទះតែអំពើអាក្រក់ លុះតែកាលណាអំពើល្អឲ្យផល កាលនោះមនុស្សល្អ ទើបបានជួបនឹងអំពើល្អ ។

២៥ – ផលបុណ្យក្តី ផលបាបក្តី សុទ្ធតែកើតមកពីកម្ម ដែលបុគ្គលធ្វើហើយ ផលនៃកម្មនោះត្រូវតែអ្នកធ្វើទទួលយកនឹងប្រកែកពុំបាន ។

– អ្នកប្រាជ្ញតាំងខ្លួនឲ្យមានព្រះពុទ្ធជាដើមទ្រង់ត្រាស់ថា៖

២៦ – ម្នាលព្រាហ្មណ៍ សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាមរតក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរឭក បើគេធ្វើនូវកម្មណា ទោះជាបុណ្យក្តី ជាបាបក្តី ក៏ត្រូវទទួលយកនូវផលនៃកម្មនោះ ។

២៧ – បាបកម្មទាំងឡាយ គឺបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ និង សុរាមេរយ តែងឲ្យផលអាក្រក់ ដែលជាមូលហេតុ នៃកំណើតក្នុងមហានរក ។

www.budinst.gov.kh www.elibraryofcambodia.org

ខណៈដែលទាំងឡាយតប្រែយល់ជាអំពើអាក្រក់តែងនាំវិញ្ញាណក្ខន្ធទៅកាន់ទុគ្គតិភព ដូច្នេះត្រូវតែជៀសវាងនូវអំពើទាំងនោះ ដើម្បីធ្វើខ្លួនឲ្យរួចចាកបទុក្ខភ័យ ។

៤៨ – បុញ្ញកម្មគឺការសាងនូវអំពើជាកុសល តែងឲ្យផលល្អដល់ជនអ្នកធ្វើ គ្រាន់តែឆាប់រហ័សនិងយឺតយូរជាងគ្នា ដែលជាមូលហេតុនៃការកើតក្នុងស្ថានសួគ៌ ។ រួមសេចក្តីថា៖

៤៩ – សត្វទាំងឡាយត្រូវទទួលយកនូវ **ផលបុណ្យ** និង **ផលបាប** តាមសមគួរ ដល់អំពើដែលខ្លួនធ្វើ សត្វណាធ្វើនូវអំពើបាប សត្វនោះត្រូវទៅកើតក្នុងនរក សត្វណាធ្វើនូវអំពើបុណ្យ សត្វនោះត្រូវទៅសោយសុខក្នុងសុគតិភព ។

បពិត្រព្រះសម្មតិទេព ស្លោកទាំងឡាយដែលព្រះអង្គទ្រង់ព្រះសណ្ដាប់នេះ គ្រាន់តែជាគ្រឿងដាស់ព្រះស្មារតី

អាស្រ័យហេតុនេះហើយអាត្មាភាព«ព្រះធម្មបាទីប»សូមរំឭកព្រះអង្គថា ៖

៣០ - ចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក, កុំយករបស់ដទៃជាទីរលឹក, ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយករបស់ដទៃជាទីរលឹកឡើយ ។

ភ្នំពេញថ្ងៃទី ៣ ឧសភា ១៩៦៦

ជាអនុស្សាវរណៈនៃក្រសួងហិរញ្ញវត្ថុ ក្នុងពិធីឈាបនកិច្ចសពសហជីវិន ហោខ-យ៉ាន់ កាលពីថ្ងៃទី ២ មិថុនា ១៩៦៧

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org